**សុន្ទរកថា មិន និងមតិផ្ដាំផ្ញើ**
**សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ក្នុងសិក្ខាសាលាបូកសរុប ការងារយេនឌ័រ**
**និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រដើម្បីបញ្ជ្រាបយេនឌ័រ ២០១៨-២០២៣ របស់ក្រសួងមហាផ្ទៃ**
**ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧**

លោកជំទាវ ឯកឧត្ដម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អភិបាល អភិបាលរង រាជធានី-ខេត្ត ក្រុមការងារយេនឌ័រគ្រប់ថ្នាក់ ភ្ញៀវជាតិ អន្តរជាតិ និងសមាជិកអង្គសិក្ខាសាលាជាទី រាប់អាន!

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយក្នុងឱកាសបូកសរុបការងាររបស់ក្រុមការងារយេនឌ័រ ក្រសួងមហាផ្ទៃ និងការប្រកាសដាក់ឲ្យប្រើប្រាស់ ផែនការយុទ្ធសាស្ត្រដើម្បីបញ្ជ្រាបយេនឌ័រ ឆ្នាំ២០១៨-២០២៣ របស់ក្រសួងមហាផ្ទៃ ដែលស្ដែងចេញនូវកិច្ចខិតខំប្រឹងប្រែង របស់ក្រុមការងារយេនឌ័ររបស់ក្រសួង ក្នុងការខិតខំជំនះរាល់ឧបសគ្គ ដើម្បីអនុវត្ត និងឈានទៅសម្រេចគោលនយោបាយជាតិចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព តំណាក់កាលទី៥ ។

ការលើកកម្ពស់សមភាពយេនឌ័រនេះ គឺផ្អែកលើតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ពោលគឺការថែរក្សា ការពារនូវសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់ក្នុងសង្គម ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍គ្រប់វិស័យ ប្រកបដោយចីរភាព ព្រមទាំងលើកកម្ពស់វិន័យ សេចក្ដីថ្លៃថ្នូររបស់មន្ត្រីក្នុងការបំពេញភារកិច្ច ជាពិសេស ការផ្ដល់សេវាជូនប្រជាពលរដ្ឋ ប្រកបដោយការទទួលខុសត្រូវ និងសីលធម៌វិជ្ជាជីវៈ ដើម្បីជាការចែករំលែក សេចក្ដីសុខផ្លូវកាយ ផ្លូវចិត្ត និងយុត្តិធម៌សង្គមដល់ប្រជាជនកម្ពុជាគ្រប់រូប គ្រប់ភេទ គ្រប់វ័យ គ្រប់ស្ថានភាព ដោយគ្មានការរើសអើង ។

ក្រសួងមហាផ្ទៃ បានខិតខំពង្រឹង និងកែលម្អរចនាសម្ព័ន្ធ និងរបៀបរបបការងាររបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ដែលឆ្លើយតបទៅនឹងការវិវត្តន៍យ៉ាងឆាប់រហ័សរបស់សង្គម ទាំងក្នុងប្រទេស ទាំងទៅតាមរបត់នៃសាកលលោក ដែលកំពុងតែប្រែប្រួលឥតឈប់ឈរ ។ កំណែទម្រង់ទាំងឡាយ រួមទាំងកំណែទម្រង់រដ្ឋបាលដើម្បីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ជាពិសេស នៅថ្នាក់ក្រោមជាតិ ដែលត្រូវអនុវត្តតាមប្រព័ន្ធ វិមជ្ឈការ និងវិសហមជ្ឈការ

របស់រាជរដ្ឋាភិបាល មានខ្លឹមសារស៊ីជម្រៅក្នុងការកសាងនូវស្ថេរភាព និងនិរន្តរភាពក្នុងការអភិវឌ្ឍន៍គ្រប់វិស័យ ដោយមានការចូលរួម ប្រកបដោយបរិយាប័ន្ន និងគណនេយ្យភាពសង្គមយ៉ាងពិតប្រាកដ ។ មន្ត្រីដែលជាអ្នកផ្តល់សេវាសាធារណៈ និងប្រជាជនជាអ្នកទទួលសេវា បានផ្លាស់ប្តូរទស្សនៈ និងឥរិយាបថ ឲ្យកាន់តែថ្មៃថ្នូរ មានការទទួលខុសត្រូវ និងតម្លាភាពខ្ពស់ ដែលជម្រុញឲ្យការចូលរួមកាន់តែច្រើនពីប្រជាពលរដ្ឋ ដោយបានយល់ និងចេះអនុវត្តករណីយកិច្ចជាពលរដ្ឋ ចេះគោរពច្បាប់ ហើយទទួលបានផលប្រយោជន៍ប្រកបដោយសមធម៌ និងមិនមានការរើសអើងពីគោលនយោបាយជាតិនានា ។

ក្នុងតួនាទីជាប្រទេសហត្ថលេខីនៃអនុសញ្ញាសហប្រជាជាតិក្នុងការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិកុមារ ជាពិសេស អនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងស្ត្រី(CEDAW) រាជរដ្ឋាភិបាលកម្ពុជាក៏បាននិងកំពុងធ្វើការងារយ៉ាងសកម្មតាមរយៈការបង្កើតនូវយន្តការពិសេស ដែលមានរចនាសម្ព័ន្ធនៅគ្រប់ថ្នាក់ គ្រប់កម្រិត គ្រប់វិស័យ ក្នុងនោះមានទាំងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី(CNCW) ក្រសួងកិច្ចការនារី(MoWA) ក្រុមការងារបច្ចេកទេសយេនឌ័រ(TWG-G) ក្រុមការងារបញ្ជ្រាបយេនឌ័រតាមបណ្តាក្រសួង-ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយធ្វើការផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹង និងធ្វើការផ្លាស់ប្តូរ ការគិតឥរិយាបថការងារ ដោយលុបបំបាត់នូវទស្សនៈប្រកាន់ រើសអើង និងការប្រមាថមាក់ងាយមនុស្សផងគ្នា ដែលជាដើមហេតុនៃទំនាស់ អំពើហិង្សា និងការប្រកាន់បែងចែកឋានៈក្នុងសង្គម ហើយមនុស្សខ្លះក៏ក្រអឺត ក្រទម មិនព្រមអើពើ និងទទួលការណែនាំ ឬមិនព្រមអនុវត្តច្បាប់ ។

ក្នុងន័យនេះ ក្រសួងមហាផ្ទៃ បាន និងកំពុងបន្តអនុវត្តគោលនយោបាយជាតិទាំងឡាយយ៉ាងយកចិត្តទុកដាក់ ជាពិសេស យុទ្ធសាស្ត្រជាតិចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ផែនការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយផ្សាភ្ជាប់តួនាទីភារកិច្ចរបស់ក្រសួងមហាផ្ទៃ ទៅនឹងការផ្តល់សេវាជូនប្រជាពលរដ្ឋនៅគ្រប់ផ្នែកពាក់ព័ន្ធ ទៅតាមផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ក្រសួង រហូតទទួលបានការចូលរួម គាំទ្រកាន់តែច្រើន និងធ្វើឲ្យប្រជាពលរដ្ឋគ្រប់ទិសទី ជាពិសេស ស្ត្រី និងកុមារ ជនចាស់ជរា ជនពិការ ជនរងគ្រោះគ្រប់មុខសញ្ញា ទទួលបានការយកចិត្តទុកដាក់កាន់តែច្រើនថែមទៀតពីអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ ។

ដោយឡែក ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការប្រមូលផ្តុំ និងចងក្រងបណ្តាញសាខាជាក្រុមការងារយេនឌ័រតាមបណ្តាថ្នាក់អគ្គនាយកដ្ឋាន ទាំងផ្នែករដ្ឋបាល ស៊ីវិល កងកម្លាំងនគរបាលជាតិ និងផ្នែកពន្ធនាគារ ដែលជាវិស័យធំទាំងបី នៃក្រសួងមហាផ្ទៃ និងមានភារកិច្ចចាំបាច់ក្នុងការកំណត់នូវបទដ្ឋាន និងគោលការណ៍នានា ក្នុងការលើកកម្ពស់សម

ធម៌ និងសមភាពយេនឌ័រ តាមរយៈការបញ្ជ្រាបទស្សនៈយេនឌ័រ ក្នុងការរៀបចំច្បាប់ គោលនយោបាយ នានារបស់ក្រសួងមហាផ្ទៃ ។

តាមរបាយការណ៍របស់ក្រុមការងារយេនឌ័រ ក៏ដូចជាទិន្នន័យដែលឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រដើម្បីបញ្ជ្រាបយេនឌ័រ ឆ្នាំ២០១៨-២០២៣ បានបង្ហាញឲ្យឃើញថា ការខិតខំប្រឹងប្រែងរបស់យើង នៅមិនទាន់ឆ្លើយតបទៅនឹងបំណងប្រាថ្នា ក្នុងការបង្កើតនូវសង្គមមួយដែលមានសមភាពយេនឌ័រសម្រាប់មនុស្សគ្រប់រូប គ្រប់ភេទ គ្រប់វ័យ ទទួលបាននូវសមធម៌ ក្នុងការចូលរួម និងការទទួលបាន នូវសិទ្ធិ ឱកាស ផលប្រយោជន៍ និងយុត្តិធម៌សង្គម នៅឡើយទេ ។ ដូច្នេះ ចាំបាច់ណាស់ ដែលយើងទាំងអស់គ្នាត្រូវចូលរួម ធ្វើឲ្យគោលដៅ និងទស្សនៈវិស័យនេះអាចសម្រេចបាន ។

យើងទាំងអស់គ្នាបានដឹងហើយថា ការធ្វើឲ្យសម្រេចគោលដៅនេះ មិនអាចកើតឡើងដោយឆាប់រហ័សបានទេ ព្រោះជាការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថសង្គមទាំងមូល ។ តែទោះបីជាយ៉ាងនេះក្តី ក៏យើងមិនត្រូវបោះបង់ដែរ គឺចាំបាច់ត្រូវតែជម្រុញ ឲ្យទៅមុខជាបណ្តើរៗ ពោលគឺ កំណើននៃការចូលរួម និងការទទួលបាននូវ សិទ្ធិ ឱកាស ផលប្រយោជន៍ និងយុត្តិធម៌សង្គម ត្រូវតែធ្វើឲ្យបាន ដោយមិនត្រូវបណ្តែតបណ្តោយ ឲ្យអត្រានេះធ្លាក់ចុះឡើយ ។ គ្រប់មុខព្រួញនៃការទទួលខុសត្រូវ ត្រូវតែខិតខំរកយុទ្ធវិធី ក្នុងការកែលម្អ របៀបរបបការងារ ជម្រុញ លើកទឹកចិត្ត និងធ្វើឲ្យមានកំណើនអត្រានៃការចូលរួម ជាពិសេស ការជ្រើសរើសមន្ត្រីថ្មី ការដាក់បញ្ចូលក្នុងក្របខណ្ឌ និងការទទួលបាននូវឋានៈ តួនាទី និងមុខតំណែងរបស់ស្ត្រី ឲ្យមានកំណើនឡើងជាលំដាប់នៅគ្រប់កម្រិត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយខិតខំជួយណែនាំ ផ្តល់ឱកាសឲ្យស្ត្រីបានកសាងសមត្ថភាព និងវាយតម្លៃពីគុណសម្បត្តិការងារឲ្យបានត្រឹមត្រូវ និងដោយស្មើភាពជាមួយបុរស ។ ស្ត្រី មានចំណុចខ្សោយតែមួយគត់ គឺកម្លាំងកាយ តែកម្លាំងចិត្ត កម្លាំងបញ្ញា ស្មារតី ការទទួលខុសត្រូវ និងការតស៊ូអំណត់ព្យាយាម គឺជាចំណុចខ្លាំងរបស់ស្ត្រី ។ ដូច្នេះ យើងមិនអាចមើលរំលងលើសមត្ថភាពស្ត្រី ក្នុងការបំពេញភារកិច្ច ក្នុងអង្គភាព ស្ថាប័នបានឡើយ ។

ខ្ញុំសូមលើកទឹកចិត្ត ដល់ស្ត្រី ដែលជាមន្ត្រី និងថ្នាក់ដឹកនាំគ្រប់កម្រិត ក្នុងវិស័យទាំងបី របស់ក្រសួងមហាផ្ទៃ គឺវិស័យរដ្ឋបាលស៊ីវិល កងកម្លាំងនគរបាលជាតិ និងវិស័យពន្ធនាគារ បន្តខិតខំជម្រុញ អនុវត្តភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវ នៅតាមបណ្តាអង្គភាព ស្ថាប័នរៀងៗខ្លួន ។ ខ្ញុំក៏សូមណែនាំ ឲ្យប្រធានអង្គភាព ស្ថាប័ន នីមួយៗ គប្បីពិនិត្យ វាយតម្លៃឲ្យបានត្រឹមត្រូវ និងមានតម្លាភាព ក្នុងការធ្វើសេចក្តីសម្រេចអំពីការដាក់បញ្ចូល ការតែងតាំង ការតម្លើងឋានៈតួនាទីស្ត្រី ដោយត្រូវមានតំណាងក្រុមការងារយេនឌ័រតាមបណ្តាអង្គភាពចូលរួម ផ្តល់យោបល់អំពីការ

វាយតម្លៃលើគុណសម្បត្តិ និងលក្ខណៈសម្បត្តិរបស់មន្ត្រីស្ត្រីនៅតាមបណ្តាអង្គភាព ដើម្បីជាបង្អែកក្នុងការធ្វើសេចក្តីសម្រេច ។ ធ្វើបែបនេះ នឹងអាចធានាចំពោះ ការបាត់បង់ឱកាសរបស់ស្ត្រី និងមិនមានការមើលរំលងចំពោះស្ត្រីដែលមានសមត្ថភាព និងគុណសម្បត្តិគ្រប់គ្រាន់នោះទេ ។

ដោយឡែក ក្នុងការជ្រើសរើសមន្ត្រីថ្មី ខ្ញុំសូមលើកទឹកចិត្ត ដល់បណ្តាអង្គភាពស្ថាប័នក្រោមចំណុះក្រសួងមហាផ្ទៃ ត្រូវខិតខំបង្កើតយុទ្ធវិធី ក្នុងការស្រូបយកកម្លាំងថ្មីជាស្ត្រីឲ្យបានច្រើន ព្រោះជាសេចក្តីត្រូវការដែលមិនអាចខ្វះបាន ក្នុងការបំពេញភារកិច្ច ជាពិសេស ការបម្រើសេវាផ្ទាល់ជាមួយប្រជាពលរដ្ឋ ដែលមានទាំងបុរស និងស្ត្រីនៅទីនោះ ។

ចំពោះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលពុំមានស្ត្រីក្នុងតួនាទីសំខាន់ៗ ក៏គប្បីពិនិត្យ លទ្ធភាព ក្នុងការដាក់បញ្ចូល និងតម្លើងឋានៈតួនាទីស្ត្រីឲ្យបានសមស្រប ដោយវាយតម្លៃទៅលើសមត្ថភាព ឆន្ទៈ ការប្តេជ្ញាចិត្ត ភាពក្លាហាន ការទទួលខុសត្រូវ និងភាពស្មោះត្រង់ និងផ្តល់ការលើកទឹកចិត្តឲ្យបានសមស្រប និងប្រកបដោយសមធម៌ជាមួយមន្ត្រីជាបុរស ជៀសវាង ភាពលម្អៀង ដែលនាំឲ្យមានការប្រៀបធៀប មិនសមហេតុផល ។ ស្ត្រីជាច្រើនបាន និងកំពុងតែបង្កើនសមត្ថភាព មានចំណេះដឹង និងចំណេះធ្វើគ្រប់គ្រាន់ ដែលអាចពិនិត្យលទ្ធភាពជ្រើសរើស និងដាក់បញ្ចូលបាន ដោយគ្រាន់តែបំប៉នបន្ថែមលើមុខជំនាញ និងការទទួលខុសត្រូវ ក្នុងនាមជាមន្ត្រីរាជការតែប៉ុណ្ណោះ ។

ខ្ញុំសង្ឃឹមថា ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ២០១៨-២០២៣ របស់ក្រសួងមហាផ្ទៃនឹងក្លាយទៅជាមូលដ្ឋានបង្អែក ក្នុងការអនុវត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ដែលជាយុត្តិធម៌សង្គម និងការកសាងនូវភាពសុខដុមរមនាក្នុងក្រសួងមហាផ្ទៃ និងដោយឡែកក្នុងសង្គមជាតិទាំងមូល តាមរយៈការផ្លាស់ប្តូរទស្សនៈ និងរិយាបថការងាររបស់មន្ត្រីយើង ។

ជាទីបញ្ចប់នេះ ខ្ញុំសូម ជូនពរបវរមហាប្រសើរ សូមលោកជំទាវ ឯកឧត្តម លោក លោកស្រី សមាជិក សមាជិកានៃអង្គសិក្ខាសាលា និងមន្ត្រីរាជការទាំងអស់ សូមបានប្រកបដោយសេចក្តីសុខ គ្រប់ប្រការ និងជោគជ័យក្នុងជីវិតការងារ និងគ្រួសារ គ្រប់ៗគ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ ផែនការយុទ្ធសាស្ត្រដើម្បីបញ្ជ្រាបយេនឌ័រ ២០១៨-២០២៣ និងផែនការសកម្មភាព២០១៧-២០២១ ចាប់ពីពេលនេះតទៅ ។

សូមអរគុណ